# សិលាចារឹកប្រាសាទខ្នារ ខេត្តឧត្តរមានជ័យ

ប្រាសាទខ្នារ មានទីតាំងស្ថិតនៅតាមបណ្ដោយខ្នងភ្នំដងរែក ព្រំដែនខ្មែរ-សៀម ត្រង់ភូមិសាស្ត្រភូមិត្រពាំងម្អមសែនជ័យ សង្កាត់បន្សាយរាក់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ដែលជាប់ព្រំប្រទល់ជាមួយស្រុកកាប់ជើង ខេត្តសុរិន្ទ្រ ប្រទេសសៀម។ ប្រាសាទនេះ អាចរាប់បញ្ចូលថាជាប្រាសាទមានទំហំធំមួយ សង់អំពីថ្មភក់ ថ្មបាយក្រៀម និងឥដ្ឋ ដែលមានប្រាង្គសរុបចំនួន ៥ បែរមុខទៅទិសខាងកើត និងមានអគារបណ្ណាល័យចំនួន ២ បែរមុខទៅរកប្រាសាទ ហើយទំនងជាទេវស្ថានព្រហ្មញ្ញសាសនាដែលសង់នៅរវាងស.វ.ទី១០-១១។ ទោះបីជាប្រាង្គនីមួយៗដែលសង់អំពីឥដ្ឋបានបាក់បែកទាំងស្រុង និងនៅសល់តែកំពែងថ្មបាយក្រៀមយ៉ាងនេះក្តី ក៏មាននៅសេសសល់គ្រឿងបង្គុំផ្សេងៗនៃប្រាសាទមួយចំនួនដូចជា ផ្តែរ សសរពេជ្រ ជើងទម្រ និងសិលាចារឹកមួយផ្ទាំងផងដែរ។ តើសិលាចារឹករកឃើញនៅប្រាសាទខ្នារ មានខ្លឹមសារ និងអត្ថន័យយ៉ាងដូចម្តេចខ្លះ?

សិលាចារឹកនេះ ចារឹកនៅលើបន្ទះថ្មភក់មេទ្វារ កំពុងរក្សាទុកនៅទីតាំងដើម ប៉ុន្តែបានបាក់បែកត្រង់ផ្នែកខាងលើ និងនៅសល់តែអក្សរចំនួន ៩ បន្ទាត់ប៉ុណ្ណោះ។ ដោយសារតែភាពរេចរឹល និងបាត់អក្សរមួយចំនួន យើងពិបាកក្នុងការអានខ្លឹមសារទាំងមូលណាស់ តែយ៉ាងណាយើងនៅអាចកំណត់ខ្លឹមសារសង្ខេបជារួមរបស់សិលាចារឹកនេះបាន។ នៅត្រង់បន្ទាត់ខាងលើ នៅមានបន្សល់ឃ្លាមួយចំនួន "**ធូលីជើងវ្រះកម្រតេងអញ**" ដែលអាចសន្និដ្ឋានថា ជាព្រះរាជសាសន៍ (រាជឱង្ការត្រាស់បង្គាប់បញ្ជារបស់ព្រះរាជា) ដល់មន្ត្រីណាម្នាក់ ឬឥស្សរជននយោបាយណាមួយ ដើម្បីឱ្យមកសាងសង់សំណង់ទេវស្ថាន ឬនាំយកតង្វាយជាមូលនិធិសម្រាប់ទ្រទ្រង់ទេវស្ថាននេះ។ រីឯអក្សរដែលអាចមើលបាននៅផ្នែកខាងក្រោម គឺសុទ្ធសឹងជាគ្រឿងតង្វាយ និងឯកតារង្វាស់រង្វាល់ ដូចជា សម្លៀកបំពាក់ ជាដើម។

## អត្ថបទចារឹក

១. ...............តធូលីជេងវ្រះ

២. កម្រតេងអញ

៣. តិប្រែតំកាល្វកាល្បជា

អត្ថបទដោយ៖ កំ វណ្ណារ៉ា

៤. ពោហប្វ៌ក្សត្រ.......

៥. ចាំជាំអ្នកាថ្ងៃ ........សជ័

៦. គោលដៃតិលេ

៧. យចន្ទ្យកា១លិជ័ ....

៨. តិលេយ ..មាន ..

៩. ជ័

ជារួមមក ទោះបីសិលាចារឹករកឃើញប្រាសាទខ្នារ ខេត្តឧត្តរមានជ័យ បានបាក់បែកផ្នែកខាងលើ និងបាត់បង់អក្សរចារឹកជាច្រើនក្តី សំណេរដែលនៅសល់បានប្រាប់ឱ្យយើងដឹងអំពីព្រះរាជឱង្ការត្រាស់បញ្ជារបស់ព្រះរាជា បង្គាប់ដល់ឥស្សរជននយោបាយណាម្នាក់ ដែលប្រហែលបញ្ជាឱ្យកសាង ឬថ្វាយតង្វាយចំពោះទេវស្ថាន។ ពោល ជារួមមក ខ្លឹមសារគឺឃ្លាតមិនឆ្ងាយអំពីការធ្វើបុណ្យ និងការមានជំនឿចំពោះទេវស្ថានសាសនា។

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ១៖ កំពែងប្រាសាទខ្នារ ខេត្តឧត្តរមានជ័យ (រូបថត៖ ផុន កសិកា)



រូបលេខ២៖ វត្ថុសិល្បៈបុរាណដែលសេសសល់នៅប្រាសាទខ្នារ

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៣៖ សិលាចារឹករកឃើញនៅប្រាសាទខ្នារ

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៤៖ សំណៅផ្ដិតសិលាចារឹកប្រាសាទខ្នារ (ផ្ដិតដោយ៖ កំ វណ្ណាវ៉)

អត្ថបទដោយ៖ កំ វណ្ណាវ៉

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ កំ វណ្ណារ៉ា